
កងការពារមិនបានកម្រៃ

The Unpaid Guards





ដើមឡើយ នៅគ្រប់សួនច្បារ សួនបន្លែនានា តែងមាន
នូវកង្កែប ហ៊ឹង កង្កែបអាចម៍គោ កញ្ឆាញ់ចេក គីង្គក់ ...
ទាំងហ្វូងៗរស់នៅ ។

In the past, our gardens were populated by many kinds of frogs.



ពួកគេរស់នៅក្នុងវាលស្រែផងដែរ ។ នៅរដូវវស្សា
ពេលគោចូលក្រោល ក្អាត់ទាំងឡាយយំកងរំពង
ហាក់ដូចប្រាប់ថា រាត្រីកាលនឹងចូលមកដល់ហើយ ។

The frogs also lived in the rice fields. In the rainy season,
in the evening when the cows went to the shed,
ka-ats cried loudly to announce the night to come.



រាល់យប់ ពេលមានភ្លៀងធ្លាក់ កង្កែប ហ៊ឹង
យំទ្រហឹងអឺងអាប់ ។ ភាពត្រជាក់ គួបផ្សំនឹងសំលេង
ទាំងនេះញ៉ាំងអោយបរិយាកាសមនោរម្យណាស់ ។

Every night, when it rained, frogs welcomed the rain with their loud voices. This noisy sound and the cool temperature made the people feel good.



សត្វទាំងនេះមានប្រយោជន៏ណាស់ ។

វាចាប់សត្វល្អិតចង្រៃទាំងឡាយស៊ីជាអាហារ ។

ពួកគេជាកងការពារដ៏ល្អ ជាកងការពារដែលមិនទារកំរៃ ។


These animals were very useful. They ate pests.
They were very good guards and they never asked for any payment.



គ្មានសត្វចង្រៃបំផ្លាញ បន្លែតាមសួននានា

ស្រូវតាមស្រែលូតលាស់បានល្អ .....

With no pests, the vegetables and rice grew well....



ហើយផ្តល់ផលជាស្លឹក ផ្កា ផ្លែ គ្រាប់ដ៏មាន

រសជាតិឆ្ងាញ់ពិសារ ។

And produced delicious leaves, flowers, fruits and grain.



ប៉ុន្តែ មនុស្សទាំងឡាយរមិលគុណណាស់ ។
ពួកគេមិនត្រឹមតែមិនបានថែរក្សាសត្វទាំងនេះទេ
ប៉ុន្តែគេបានសំលាប់ពួកវាធ្វើជាអាហារ និងលក់យកប្រាក់ ។

But people were very ungrateful. They did not only take care of the frogs, but they also killed them to eat and to sell.



គេចាប់សត្វទាំងនេះតាំងពីឧបករណ៍ធម្មតាដូចជា

សន្ទូច អង្រុត លប រហូតដល់អាគុយដែលជា

ឧបករណ៍សំលាប់ផ្តាច់ពូជ ។

To kill them, they used all local instruments such as the santouch, the angrut, the lorp. And they used the genocide instrument, the electric battery.




បច្ចុប្បន្ននេះ ពូជសត្វទាំងនេះរលាយអស់ហើយ ។

អស់ហើយសំលេងក្អាត់យំពេលល្ងាច !

អស់ហើយសំលេងហ៊ឹងយំពេលភ្លៀងធ្លាក់ !

ច្បារដំណាំ វាលស្រែ អស់មានកងការពារទៀតហើយ !


Today these frogs have become almost extinct.
No more ka-ats cry at the sunset!
No more frogs cry at the rain!
No more guards in the gradens and rice fields!



សត្វល្អិតចង្រៃក៏ឡើងដៃ ។


ពួកវាស៊ីនិងបំផ្លាញដំណាំ តាមអំពើចិត្ត ។

Pests have now become powerful.
They eat and destroy the plants at will.



ដើម្បីការពារដំណាំរបស់ខ្លួន កសិករតែងរត់រកថ្នាំគីមី

To protect the plants, farmers use pesticides.



ថ្នាំគីមីមានផលវិបាកអាក្រក់ច្រើនណាស់ ។


វាមានតំលៃថ្លៃ ដូចនេះប្រាក់ចំណូលពីផលដំណាំក៏ធ្លាក់ចុះ ។

The chemical pesticides have a very negative impact.
They are expensive. So there is less income from the plants.



ថ្នាំគីមីមានជាតិពុល ។ កសិករមានគ្រោះថ្នាក់ដោយសារ
ការប្រើប្រាស់វាដោយគ្មានប្រដាប់ការពារ ។

The chemical pesticides are poisonous.
So, using them without protector make the farmers very sick.



ថ្នាំគីមីបំពុលបរិស្ថានថែមទៀត ។

ហើយបើបរិស្ថានពុលហើយនោះ មនុស្សក៏ពុលដែរ ។

The pesticides also poison the environment.
When the enviroment is poisoned, so are the people.



ដូចនេះ កង្កែប គឺង្គក់ ហ៊ឹង កញ្ជ្រោញចេក ...
ប្រសើរជាងថ្នាំគីមីឆ្ងាយណាស់ ។ មានពួកវាយើង
ចំណេញប្រាក់ ។

So frogs are far better than chemical pesticides.
if we have them, we save money.



មានពួកវា យើងមានបរិស្ថានស្អាត

ជួយអោយមានសុខភាពល្អ យើងមានសុខភាពល្អដែរ ។

With them, our environment is healthy and so are we.



ពួកគេជាមិត្តរបស់យើង។ ជាអ្នកការពារដំណាំរបស់យើង។
គឺជាកងការពារដែលមិនទារកំរៃ។

They are our friends. They are the guardians of our plants. The volunteer guards who ask for no payment.